00252138

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C26/5/5

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៥)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន

កាលបរិច្ឆេទ: ២៤ ធ្នូ ២០០៨

---

**សាធារណៈ**

**សេចក្តីសម្រេចលើសំណើជាយថាហេតុរបស់លោក ខៀវ សំផន សុំដោះលែងឱ្យមានសេរីភាព**

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Vincent de WILDE d'ESTMAEL

**ជនត្រូវចោទ**

ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គីម ម៉េងឃី
មុំ សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR

**សហមេធាវីការពារក្តី**

ស ស៊ីវ៉ាន
Jacques VERGÈS

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 12 / 2008
ម៉ោង (Time/Heure): 13:25
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: K.K. Ratanak

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 24 / 12 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

00252139





១. **ប្រធានអង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" បានទទួល "សំណើជាយថាហេតុ និងបន្ទាន់បំផុត ដើម្បីស្នើសុំឱ្យមានការដោះលែងឱ្យមានសេរីភាព" ("សំណើ")។ សំណើនេះ បានដាក់នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ ដោយសហមេធាវីការពារក្តីរបស់លោក **ខៀវ សំផន**។

## ជំពូក ១ - សេចក្តីផ្តើម

២. សំណើនេះបានដាក់នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទដែលប្តឹងចំពោះដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។

៣. នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៨ ប្រធានអង្គបុរេជំនុំជម្រះ បានបង្គាប់ភាគីឱ្យដាក់សេចក្តីសន្និដ្ឋានតប ចំពោះសំណើនេះ ត្រឹមថ្ងៃទី១៦ ខែធ្នូ ត្រឹមម៉ោង ៤ រសៀល។

៤. សហព្រះរាជអាជ្ញា បានដាក់សេចក្តីសន្និដ្ឋានតបមួយ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៨ ។ អង្គបុរេជំនុំជម្រះ មិនទទួលបានសេចក្តីសន្និដ្ឋានតបពីដើមបណ្តឹងរដ្ឋប្បវេណី ឡើយ។

## ជំពូក ២ - សេចក្តីសន្និដ្ឋានរបស់ភាគី

៥. ដោយផ្តល់ទឡ្ហីករណ៍ថា ជនត្រូវចោទ "បច្ចុប្បន្នកំពុងស្ថិតនៅក្រោមការឃុំខ្លួនដោយបំពាន ដោយសម្អាងលើឯកសារដែលគ្មានតម្លៃ និងក្នុងក្របខណ្ឌនៃនីតិវិធីដែលមានភាពយឺតយ៉ាវ"[១], សហមេធាវីការពារក្តី បានស្នើសុំឱ្យដាក់ជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដើម្បីជាវិធានការទប់ស្កាត់ និងវិធានការការពារ រហូតដល់ពេលចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ចំនួនបី ដែលកំពុងចាត់ការនៅចំពោះមុខអង្គបុរេជំនុំជម្រះ៖ បណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តី ចំពោះសេចក្តីសម្រេចបដិសេធ សំណើសុំបកប្រែសំណុំ

[១] សំណើជាយថាហេតុ និងបន្ទាន់បន្តិបំផុត ដើម្បីស្នើសុំដោះលែងឱ្យមានសេរីភាព ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ C26/5/2 វាក្យខណ្ឌទី ៦។

00252140

C26/5/5



រឿងលោក **ខៀវ សំផន**[២] បណ្តឹងឧទ្ធរណ៍ចំពោះដីកាបដិសេធ សំណើសុំដោះលែងឱ្យមានសេរីភាព[៣] និងបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន[៤]។ សំណើនេះ បានដាក់ជូន "ប្រធានអង្គបុរេជំនុំជម្រះ ដែលលោកមានតួនាទី ជាចៅក្រមតំណាងតុលាការ និងដោយសារអំណាចរបស់លោកជាប្រធាននៅក្នុងអង្គបុរេជំនុំជម្រះ"។ សំណើនេះបានផ្អែកលើមាត្រា ២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងចំណោមទឡ្ហីករណ៍ដែលបានលើកឡើង សហមេធាវីការពារក្តី ក៏បានយោងលើមាត្រា ៣២, ៣៨, ១0៩ (មាត្រា ១២៨(ថ្មី) នាពេលបច្ចុប្បន្ន) និង ១១0 (មាត្រា ១២៩(ថ្មី) នាពេលបច្ចុប្បន្ន) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") និងមាត្រា ៩(៤) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

៦. សហព្រះរាជអាជ្ញា សន្និដ្ឋានថា សំណើនេះគួរតែបដិសេធចោល ពីព្រោះ៖

(ក) វិធានផ្ទៃក្នុង អ.វ.ត.ក ដែលមានអានុភាពអនុវត្តលើក្រមនីតិវិធីព្រហ្មទណ្ឌនោះ ពុំអនុញ្ញាតឱ្យមានការស្នើសុំដូច្នេះចំពោះមុខ អ.ប.ជ ឬប្រធាន អ.ប.ជ ឡើយ ហេតុដូច្នេះការស្នើសុំជាបន្ទាន់ នោះពុំអាចទទួលយកបានឡើយ។

(ខ) បើមិនដូច្នោះទេ មាត្រា ២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលការស្នើសុំនេះ បានផ្អែកលើ គឺខាងមេធាវីការពារក្តីបានបកស្រាយខុស ដោយហេតុថា វាពុំអនុញ្ញាតឱ្យភាគីនានាស្នើសុំឱ្យប្រធានសភាស៊ើបសួរ (និងបើផ្អែកលើទឡ្ហីករណ៍ខ្លាំងជាងនេះ អ.ប.ជ) ទទួលបាននូវការស្នើសុំបន្ទាន់បែបនេះ ឬក៏ផ្តល់ដល់ប្រធាន អ.ប.ជ នូវអំណាចបញ្ជាឱ្យដោះលែងបណ្តោះអាសន្នយ៉ាងដូច្នេះទេ។

---

[២] បណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តី ចំពោះការបដិសេធសំណើសុំបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២00៨ A190/I/1 (អបជ១១)។

[៣] សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធការដោះលែងឱ្យមានសេរីភាព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២00៨, ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២00៨ C40/5/1 (អបជ ១៤)។

[៤] សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២00៨, C26/5/1 (អបជ ១៥)។

C26/5/15

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៥)

# ជំពូក ៣ - បទប្បញ្ញត្តិគតិយុត្ត

## ក. បទប្បញ្ញត្តិដែលក្រុមការពារក្តីយកមកធ្វើជាសម្អាង

៧. មាត្រា ២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថា៖

"ប្រធានសភាស៊ើបសួរ រ៉ាប់រងលើការប្រព្រឹត្តទៅដ៏ល្អនៃមន្ទីរស៊ើបសួរនៃចៅក្រមស៊ើបសួរ។ ប្រធានស៊ើបសួរផ្ទៀងផ្ទាត់មើលជាអាទិ៍ លក្ខខណ្ឌនៃការអនុវត្តន៍បទប្បញ្ញត្តិស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ដីកាតុលាការផ្សេងៗ ដីកាចាត់ឱ្យសួរជំនួស និងកោសល្យវិច័យ។

ប្រធានសភាស៊ើបសួររ៉ាប់រងកុំឱ្យនីតិវិធីទាំងឡាយមានការយឺតយ៉ាវដោយមិនសមហេតុផល។

ប្រធានសភាស៊ើបសួរអាចចុះទៅធ្វើអធិការកិច្ចនៅក្នុងមន្ទីរស៊ើបសួរ។

៨. មាត្រា ៣២, ៣៨, ១២៨(ថ្មី), និង១២៩(ថ្មី) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងដោយឡែកៗពីគ្នា ថា៖

**"មាត្រា ៣២:**

ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន។

[...]"

**"មាត្រា ៣៨:**

[...]"

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។"

[...]

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។

ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។"

**"មាត្រា ១២៨-ថ្មី (មាត្រា ១០៩ ចាស់)**

អំណាចតុលាការជាអំណាចឯករាជ្យ។

អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។

អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្ដីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។"

**"មាត្រា ១២៩-ថ្មី (មាត្រា ១១០ ចាស់)**

ការជម្រះក្ដីផ្ដល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន។ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្ដី។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។"

៩. មាត្រា ៩(៤) នៃ ICCPR ចែងថា:

"បុគ្គលណាដែលត្រូវបានដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវតែមានសិទ្ធិដាក់ពាក្យបណ្ដឹង ដើម្បីឱ្យតុលាការអាចសម្រេចដោយមិនពន្យារពេល អំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងបង្គាប់ឱ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់។"

## ខ. វិធានផ្ទៃក្នុង

១០. វិធាន ៦៤(២) នៃវិធានផ្ទៃក្នុង ចែងថា៖

"ក្នុងអំឡុងពេលឃុំខ្លួនបណ្ដោះអាសន្ន ជនត្រូវចោទ ឬ មេធាវីរបស់គាត់អាចធ្វើសំណើសុំឱ្យដោះលែងទៅ សហចៅក្រមស៊ើបអង្កេតបានគ្រប់ពេលវេលា។ [...] ដោយយោងទៅលើបទប្បញ្ញត្តិនៃវិធាន ៧២(២) សហចៅក្រមស៊ើបអង្កេត ត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ ក្រោយពេលទទួលបានយោបល់ពីសហព្រះរាជអាជ្ញា។ ដីកាសម្រេចនេះ បើកផ្លូវប្ដឹងឧទ្ធរណ៍។"

១១. វិធាន ៧៧(១១) និង (១៣) នៃវិធានផ្ទៃក្នុង ចែងដោយឡែកៗពីគ្នាថា៖

"១១. ដោយរង់ចាំលទ្ធផលនៃនីតិវិធីរបស់អង្គបុរេជំនុំជម្រះក្រោមវិធាននេះ និង លើកលែងតែអង្គបុរេជំនុំជម្រះ បង្គាប់ផ្សេងពីនេះ សហចៅក្រមស៊ើបអង្កេត អាចបន្តការស៊ើបសួររបស់ខ្លួននៅពេលណាដែលអាចធ្វើទៅបាន។"

១៣. សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឱ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូបយ៉ាងតិច។ [...] ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្ដីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គបុរេជំនុំជម្រះ ត្រូវអនុវត្តដូចខាងក្រោម:

00252143

C26/515



ក. ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ ឬពាក្យសុំមោឃភាពដីកា ឬកិច្ចស៊ើបសួរ ដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬកិច្ចស៊ើបសួរនោះ ត្រូវតម្កល់ទុកជាបាន។ [...]"

## ជំពូក ៤ - សេចក្ដីពិចារណា

១២. អនុលោមតាមវិធាន ៦៤(២) នៃវិធានផ្ទៃក្នុង សំណើសុំដោះលែងឱ្យមានសេរីភាព ត្រូវដាក់ទៅសហចៅក្រមស៊ើបអង្កេត ហើយបើកផ្លូវឱ្យប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។

១៣. វិធានផ្ទៃក្នុងចែងថា សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍មុនអង្គសេចក្ដី និងសំណើទាំងឡាយ ត្រូវចេញដោយអង្គបុរេជំនុំជម្រះទាំងមូល។ ប្រធានអង្គបុរេជំនុំជម្រះ សង្កេតឃើញថា អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង, ដីការបស់សហចៅក្រមស៊ើបអង្កេត អាចត្រូវបានគេមោឃៈ ឬបដិសេធចោលបាន ក្នុងករណីដែលមានសម្លេងគាំទ្ររបស់ចៅក្រម ៤(បួន) រូបរបស់អង្គបុរេជំនុំជម្រះ តែប៉ុណ្ណោះ។

១៤. វិធានផ្ទៃក្នុង មិនផ្ដល់យុត្តាធិការដល់ប្រធានអង្គបុរេជំនុំជម្រះ ក្នុងការដោះលែងជនត្រូវចោទបណ្ដោះអាសន្ន នោះទេ។[៥]

១៥. វិធានផ្ទៃក្នុងដែលបានដកស្រង់នៅក្នុងចំនុចខាងលើ ឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងកិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចព្រមព្រៀងនេះ បានបង្កើតឡើងដោយឆ្លើយតបទៅនឹងសំណើរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការសុំជំនួយចំពោះការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

[៥] អំណាចពិសេសនានាដែលផ្ដល់ដល់ប្រធាន តាមអំណាចនៃវិធានផ្ទៃក្នុង គឺមានចែងនៅក្នុងវិធាន ៥០(៣) វិធាន ៧៧(៣)(ក) និង វិធាន ៧៧(១៥) នៃវិធានផ្ទៃក្នុង។

C26/5/5



កិច្ចព្រមព្រៀងនេះត្រូវបានគេមើលឃើញថា សេចក្តីសម្រេច នឹងត្រូវធ្វើឡើងដោយក្រុមប្រឹក្សាជំនុំជម្រះ ដែលមានសមាសភាពជាតិ និងអន្តរជាតិចូលរួម។[៦]

១៦. នៅក្នុង "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ **នួន ជា** ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព" អង្គបុរេជំនុំជម្រះ បានយល់ឃើញថា:

> "១៤. ដូច្នេះ វិធានផ្ទៃក្នុងបង្កើតជាប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯង ដែលពាក់ព័ន្ធនឹងកាលៈទេសៈ ពិសេសរបស់ អ.វ.ត.ក ហើយត្រូវបានអនុម័ត និងមានការយល់ស្របពីកិច្ចប្រជុំពេញអង្គនៃអ.វ.ត.ក។ វិធានផ្ទៃក្នុងនេះមិនផ្ទុយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឡើយ ប៉ុន្តែគោលបំណងរបស់ អ.វ.ត.ក ខុសគ្នាជាសំខាន់ពីដំណើរការសាមញ្ញរបស់តុលាការព្រហ្មទណ្ឌកម្ពុជា ដែលតម្រូវឱ្យ អ.វ.ត.ក មានប្រព័ន្ធមួយដែលមានលក្ខណៈពិសេស។ ដូច្នេះ វិធានផ្ទៃក្នុងជាលិខិតូបករណ៍ចំបង ដែលយើងគួរនឹងយកមកពិនិត្យមើល ក្នុងការកំណត់នីតិវិធីនៅចំពោះមុខអ.វ.ត.ក ក្នុងករណីមានភាពខុសគ្នារវាងនីតិវិធីនៃវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។
>
> ១៥. បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាគួរយកមកអនុវត្ត ក្នុងករណីមានបញ្ហាចោទណាមួយដែលវិធានផ្ទៃក្នុងមិនមានចែងតែប៉ុណ្ណោះ។"

១៧. ដោយផ្អែកលើសេចក្តីពិចារណាទាំងនេះ ប្រធានអង្គបុរេជំនុំជម្រះយល់ឃើញថា បទប្បញ្ញត្តិនានានៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនអាចអនុវត្តបានទេ ដោយសារវិធានផ្ទៃក្នុង ចែងយ៉ាងច្បាស់ពីបញ្ហាយុត្តាធិការលើការអនុវត្តន៍ចំពោះការដោះលែងឱ្យមានសេរីភាពជាបណ្តោះអាសន្ន។

១៨. នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា, សេចក្តីសម្រេចលើការដោះ

---

[៦] សូមអានវាក្យខណ្ឌទី ៣ និងវាក្យខណ្ឌទី ៤ នៃបុព្វកថា និងមាត្រា ៣ និងមាត្រា ៤ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣។

00252145

C26/515

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៥)

លែងបណ្តោះអាសន្ន ត្រូវធ្វើឡើងដោយអង្គបុរេជំនុំជម្រះ[៧] ឬ អង្គជំនុំជម្រះសាលាដំបូង[៨]។ ប្រធានអង្គបុរេជំនុំជម្រះយល់ឃើញថា នីតិវិធីលើការដោះលែងឱ្យមានសេរីភាពជាបណ្តោះអាសន្ន ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង គឺស្របជាមួយនឹងវិធាននៃនីតិវិធីរបស់តុលាការអន្តរជាតិនានា។ ដូច្នេះ បទដ្ឋានអន្តរជាតិមិនទាមទារឱ្យបញ្ចូលលទ្ធភាពផ្សេងៗ សម្រាប់ឱ្យជនត្រូវចោទស្នើសុំការដោះលែងឱ្យមានសេរីភាព ជាបណ្តោះអាសន្ន នោះឡើយ។

១៩. ប្រធានអង្គបុរេជំនុំជម្រះយល់ឃើញថា ខ្លួនមិនមានយុត្តាធិការសម្រេចលើសំណើនេះឡើយ។ ដូច្នេះ សំណើនេះនឹងប្រកាសថា មិនអាចទទួលយកបាន។

**ហេតុដូច្នេះ ប្រធានអង្គបុរេជំនុំជម្រះ**

**សម្រេច÷**

សំណើនេះ មិនអាចទទួលយកបាន។ ៧/

ភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

ប្រាក់ គឹមសាន

[៧] វិធាន ១១៨ នៃវិធាននីតិវិធី និងភស្តុតាង របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[៨] វិធាន ៦៥(ក) នៃវិធាននីតិវិធី និងភស្តុតាង របស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី។ វិធាន ៦៥(ក) នៃវិធាននីតិវិធី និងភស្តុតាង របស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា។